រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

050KH01A-01

ចូរយើងបង្កើតក្រុមជំនុំសាខា



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥០

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រើការសិក្សានេះ ដើម្បីជំរុញអោយក្រុមជំនុំរបស់អ្នកបង្កើនចំនួនបន្ត ស្របទៅតាមព្រះហឫទ័យរបស់ព្រះអង្គ ។



កំណត់ចំណាំ :

© Project WorldReach © SEAN

- តើអ្នកនឹងបង្កើតក្រុមជំនុំនៅតំបន់ណាខ្លះ ? (អ្នកអាចធ្វើផែនទីមួយព្យួរលើជញ្ជាំង ហើយគូសសញ្ញាលើផែនទីនេះដើម្បីសំគាល់កន្លែងដែលអ្នកចង់ចាប់ផ្តើមបង្កើតក្រុមជំនុំ) ។

_____

_____

- តើអ្នកនឹងចាប់ផ្តើមក្រុមជំនុំសាខាទីមួយនៅឯណា ? ។

_____

- តើអ្នកណាខ្លះ នឹងធ្វើជាសមាជិកក្រុមបង្កើតក្រុមជំនុំរបស់អ្នក ? (ពួកគេអាចចុះឈ្មោះលើផែនទីក្បែរទីកន្លែង ដែលពួកគេចង់ផ្សាយដំណឹងល្អ) ។

_____

_____

- តើអ្នកនឹងចាប់ផ្តើមធ្វើការងារនៅទីនោះ នៅពេលណា ? ។

_____

- ត្រូវជំរុញក្រុមជំនុំរបស់អ្នក ឱ្យចាប់អារម្មណ៍លើការបង្កើតក្រុមជំនុំ ។ ត្រូវរាយការណ៍រាល់ខែអំពីការរីកចំរើនរបស់ការងារនេះ ហើយអធិស្ឋានសំរាប់ការងារនេះជាប់ជានិច្ច ។

ក្រុមជំនុំនិមួយៗត្រូវបង្កើតក្រុមជំនុំសាខាបន្តទៀត ។ បើសិនជានៅតំបន់ជិតៗមានក្រុមជំនុំផ្សេងៗទៀត ដែលអាចផ្សព្វផ្សាយដំណឹងល្អស្រាប់ហើយ ត្រូវចាត់គ្រីស្តទូតទៅតំបន់ផ្សេងទៀត ឬប្រទេសផ្សេងទៀតក៏បានដែរ ។

នៅទំព័របន្តបន្ទាប់មានសកម្មភាព សំរាប់បង្កើតក្រុមជំនុំសាខា សូមអាន កិច្ចការ ជំពូក ១០ និង ១១:១-១៨ ដែលជាមូលដ្ឋាននៃសកម្មភាពទាំងនេះ ។

ទុកឱ្យព្រះជាម្ចាស់ដឹកនាំអ្នកទៅរកមនុស្ស ដែលព្រះអង្គបានរៀបចំចិត្តហើយ ឱ្យចង់ស្តាប់ដំណឹងល្អដែលអ្នកប្រកាសប្រាប់

ក្រុមអ្នកជឿប្រាំពីរនាក់ គឺអ្នកជឿប្រាំមួយនាក់មកពីក្រុមជំនុំ នៅទីក្រុងយ៉ុបប៉េ និង សាវ័កពេត្រុសមកពីទីក្រុងយេរូសាឡឹម នាំគ្នាទៅទីក្រុងសេសារេ ហើយបង្កើតបានក្រុមជំនុំសាខាមួយ ដែលជាក្រុមជំនុំចៅរបស់ក្រុមជំនុំនៅក្រុងយេរូសាឡឹម (កិច្ចការ ជំពូក ១០) ។ កិច្ចការនេះ ចាប់ផ្តើមដោយសារការអធិស្ឋានរបស់លោកពេត្រុស និង លោកគ័រនេល្យូស ។ ព្រះជាម្ចាស់បានរៀបចំអោយពួកអ្នកជឿមានទំនាក់ទំនងជាមួយជនជាតិអ៊ីតាលី តាមរយៈលោកគ័រនេល្យូស ។

ដំបូង យើងត្រូវនាំគ្នាចេញទៅទីកន្លែង ដែលមិនទាន់បានទទួលដំណឹងល្អ គឺជាកន្លែងដែលព្រះជាម្ចាស់បានធ្វើកិច្ចការពិសេសក្នុងចិត្តមនុស្ស (គឺមនុស្សដែលជាមិត្តភក្តិ ឬ ជាសាច់ញាតិដែលយើងអាចនិយាយជាមួយបានដោយទុកចិត្ត) ។ បើសិនជាពួកគេកែប្រែចិត្តគំនិត ហើយជឿ យើងនឹងធ្វើពិធីជ្រមុជទឹកឱ្យពួកគេ ។ បើសិនជានៅក្នុងតំបន់នោះ គ្មានអ្នកណាទទួលដំណឹងល្អទេ នោះយើងត្រូវទៅកន្លែងផ្សេងទៀត (ម៉ាថាយ ១០:១៤) ។



នៅក្នុងវគ្គគម្ពីរនៅទំព័របន្ទាប់នេះ សូមគូសបន្ទាត់ពីក្រោមសេចក្តីដែលព្រះជាម្ចាស់បង្គាប់អោយលោកគំរនេល្យូសធ្វើ :

កិច្ចការដែលត្រូវអនុវត្ត

- ជួយក្រុមជំនុំរបស់អ្នកបង្កើតក្រុមជំនុំសាខា ។
- ពេលនេះ សូមអធិស្ឋាន និង រៀបចំផែនការ ។
- តើនៅក្នុងតំបន់របស់អ្នក ទីកន្លែងណាដែលគ្មានក្រុមជំនុំ ? តើក្រុមមនុស្ស ឬ ក្រុមជនជាតិណា នៅក្នុងតំបន់របស់អ្នកដែលមិនទាន់ឮដំណឹងល្អនៅឡើយ ? ។

_____

_____

- តើអ្នកមានទំនាក់ទំនងជាមួយអ្នកណាខ្លះ នៅក្នុងសង្គាត់ ឬ តំបន់ទាំងនោះ ? ។

_____

_____

_____

_____

_____

«នៅក្រុងសេសារេ មានបុរសម្នាក់ឈ្មោះគ័រនេល្យូស ជានាយ-
ទាហានក្នុងកងវរសេនាតូចរ៉ូម៉ាំងមួយ ឈ្មោះ "កងវរសេនាតូចអ៊ី
តាលី" ។ គាត់ និង ក្រុមគ្រួសាររបស់គាត់ទាំងមូល ជាអ្នកគោរព
ប្រណិប័តន៍ និង កោតខ្លាចព្រះជាម្ចាស់ ។ គាត់តែងចែកទានជា
ច្រើនអោយប្រជាជន ព្រមទាំងទូលអង្វរព្រះជាម្ចាស់គ្រប់ពេល
វេលា ។ ថ្ងៃមួយ ប្រមាណជាម៉ោងបីរសៀល គាត់បាននិមិត្ត
ឃើញទេវទូតមួយរូបរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ ទេវទូតនោះ
ចូលមកផ្ទះគាត់ ហៅគាត់ថា÷ "លោកគ័រនេល្យូសអើយ !" ។
លោកគ័រនេល្យូសសំឡឹងមើលទៅទេវទូត ហើយមានប្រសាសន៍
ទៅវិញ ទាំងភ័យខ្លាចថា÷ "លោកម្ចាស់អើយ ! តើលោកមាន
ការអ្វី ?" ។ ទេវទូតពោលមកគាត់ថា÷ "ព្រះជាម្ចាស់ទ្រង់ព្រះ-
សណ្ដាប់ពាក្យទូលអង្វររបស់លោកហើយ ព្រះអង្គក៏ជ្រាបអំពីទាន
របស់លោកដែរ ព្រះអង្គមិនភ្លេចទេ ។ សុំលោកចាត់គេអោយទៅ
ក្រុងយ៉ុបប៉េឥឡូវនេះ អញ្ជើញបុរសម្នាក់ឈ្មោះស៊ីម៉ូន ហៅពេត្រុស
/សិលាមក ។ គាត់ស្នាក់នៅផ្ទះអ្នកសម្លាប់ស្បែកម្នាក់ឈ្មោះ ស៊ីម៉ូន
ផ្ទះនោះនៅក្បែរមាត់សមុទ្រ" » ។

១៣- លោកពេត្រុស និង មិត្តភ័ក្តិរួមដំណើររបស់គាត់ស្នាក់នៅពីរបីថ្ងៃ ដើម្បីរៀបចំពួកគ្រីស្តជនថ្មីនៅក្រុងសេសារេ ។ សាវ័កប៉ូលក៏យកចិត្តទុកដាក់ណែនាំពួកអ្នកជឿថ្មី និងរៀបចំពួកអ្នកដឹកនាំមូលដ្ឋានរបស់ក្រុមជំនុំថ្មីដែរ ។ តើអ្នកមានផែនការដូចម្តេច ដើម្បីរៀបចំពួកអ្នកដឹកនាំថ្មីនៅក្នុងក្រុមជំនុំ ដែលអ្នកជួយបង្កើត ? ។



«កាលទេវទូត ដែលបាននិយាយជាមួយគាត់ ចេញផុតទៅ លោកគ័រនេល្យូសក៏ហៅអ្នកបំរើពីរនាក់ និង ទាហានម្នាក់ដែលនៅក្រោមបញ្ជារបស់គាត់ជាយូរហើយ ហើយគោរពប្រណិប័តន៍ព្រះជាម្ចាស់ផងនោះ ឱ្យចូលមក ។ លោកបានរៀបរាប់ហេតុការណ៍ទាំងអស់ប្រាប់ពួកគេ រួចចាត់អោយទៅក្រុងយ៉ុបប៉េ» ។

(កិច្ចការ ១០:១-៨)

១១- ពួកអ្នកជឿថ្មីបានទទួលអំណោយទាន ដូចពួកសាវ័កដែរ (កិច្ចការ ២:៤, ១០:៤៤-៤៦, កិច្ចការ ១១:១៧) ។ តើពួកសាវ័កធ្វើអ្វី ដើម្បីណែនាំប្រមូលពួកអ្នកជឿថ្មីឱ្យបំរើព្រះជាម្ចាស់ក្នុងក្រុមជំនុំ និង ផ្សាយដំណឹងល្អដល់មនុស្សឯទៀត (១ កូរិនថូស ១២:៤-១១) ?

☐ លើកទឹកចិត្តពួកគេឱ្យបំពេញមុខងារបំរើផ្សេងៗ ស្របទៅតាមអំណោយទាន ដែលព្រះជាម្ចាស់ប្រទានឱ្យ ។

☐ ចាត់ពួកគេទាំងអស់អោយរួមគ្នា បំពេញមុខងារតែមួយប៉ុណ្ណោះ ។

១២- នៅក្នុង កិច្ចការ ជំពូក ១១ លោកពេត្រុសបានត្រូវគេទិតៀនដោយសារលោកធ្វើកិច្ចការបំរើក្នុងចំណោមពួកសាសន៍ដទៃ ។ តាមមើលទៅ មារសាតាំងតែងតែវាយតបស្នើរគ្រប់ពេលចំពោះក្រុមជំនុំ ដែលកំពុងចាប់ផ្តើមបង្កើនចំនួនបន្តនៅក្នុងផែនដីរបស់វា ។ ដូច្នេះ ត្រូវត្រៀមខ្លួនជា ស្រេច ! ។ តើមានផែនការដូចម្តេច ដើម្បីទប់ទល់នឹងមារសាតាំង ពេលវាវាយប្រហារពួកអ្នកបង្កើតក្រុមជំនុំ ? ។

© Project WorldReach © SEAN

☐ ចាប់តាំងពីដំបូង ពួកសាវ័កបង្រៀនពួកអ្នកជឿថ្មី អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះយេស៊ូ ព្រមជាមួយនឹងសេចក្តីបង្រៀនអំពីគោល-ជំនឿ ដូចជា ការកែប្រែចិត្តគំនិត ការទទួលពិធីជ្រមុជទឹក ការស្រឡាញ់គ្នាទៅវិញទៅមក ការចូលរួមធ្វើពិធីកាច់នំប៉័ង ការអធិស្ឋាន ការសិក្សាព្រះបន្ទូល ការដាក់ដង្វាយ ការព្យាយាមក្នុងជំនឿ និង ការផ្សាយដំណឹងល្អ ។

១០- ពេលលោកពេត្រុសចាប់ផ្តើមបង្រៀនពួកគេ អំពីព្រះយេស៊ូ ស្រាប់តែមានការអស្ចារ្យកើតឡើង ដើម្បីធ្វើអោយលោកពេត្រុស និង មិត្តភ័ក្តិជាតិយូដារបស់គាត់ ជឿជាក់ថា ពួកសាសន៍ដទៃពិតជាបានកើតជាថ្មីមែន ។ តើមានអ្វីកើតឡើង យោងទៅតាមបទគម្ពីរ កិច្ចការ ១០:៤៤-៤៦ ?

☐ ពួកអ្នកជឿថ្មីនោះទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ព្រមទាំងចាប់ផ្តើមសរសើរតម្កើងព្រះជាម្ចាស់ជាភាសាដទៃ ។

☐ ពួកសាវ័កចាត់លោកគ័រនេល្យូស ទៅសាលាព្រះគម្ពីរនៅទីក្រុងយេរូសាឡឹម ។

នាយទាហានរ៉ូម៉ាំងឈ្មោះគ័រនេល្យូស ជាមនុស្សដែលគោរពកោតខ្លាចព្រះជាម្ចាស់ និង ប្រតិបត្តិតាមព្រះជាម្ចាស់ដែរ តែគាត់មិនដែលបានឮអំពីព្រះនាមរបស់ព្រះយេស៊ូទេ ។

តើលោកគ័រនេល្យូសត្រូវអញ្ជើញអ្នកណា ពីទីក្រុងយ៉ុបប៉ែ ? ។

យើងត្រូវតែបើកចិត្តទទួលបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សំរាប់ជីវិតយើង ទោះបីជាព្រះហឫទ័យរបស់ព្រះអង្គខុសពីការដែលយើង « គិត » យ៉ាងណាក៏ដោយ ។

ព្រះជាម្ចាស់ចាត់អោយលោកពេត្រុសទៅផ្សាយដំណឹងល្អប្រាប់លោកគ័រនេល្យូស ព្រោះលោកគ័រនេល្យូសជាមនុស្សដែល :

☐ ធ្វើជានាយទាហាន ។

☐ អធិស្ឋានទៅព្រះជាម្ចាស់ ។

ព្រះជាម្ចាស់ក៏បានកែប្រែវិធីបទរបស់លោកពេត្រុស នៅពេលដែលលោកអធិស្ឋានដែរ ។ តាំងពីលោកពេត្រុសនៅក្មេង លោកបានទទួលការទូន្មានថា លោកជាជនជាតិយូដា មិនត្រូវទាក់ទងជាមួយសាសន៍ដទៃទេ ។ បើសិនជាព្រះជាម្ចាស់មិនបានដកចិត្ត

គំនិតប្រកាន់ពូជសាសន៍នេះចេញពីលោកពេត្រុស លោកប្រហែលជាមិនទៅទីក្រុងសេសារេទេ (កិច្ចការ ១០:២៨-២៩) ។



នៅក្នុងអត្ថបទព្រះគម្ពីរនៅទំព័របន្ទាប់នេះ សូមគូសបន្ទាត់ពីក្រោម :

១) សេចក្តីដែលជាព្រះសូរសៀងបង្គាប់លោកពេត្រុស ។

២) ពាក្យប្រកែករបស់លោកពេត្រុស ។

៣) ចម្លើយរបស់ព្រះជាម្ចាស់ចំពោះពាក្យប្រកែករបស់ពេត្រុស ។

៨- ពួកគេមិនបាច់រង់ចាំ ឬ«រលាស់ធូលីចេញពីជើង» ហើយដើរចេញពីទីនោះទេ ពីព្រោះពួកគេឃើញជាក់ស្តែងអំពីកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ដូចនេះ ពួកគេអាចធ្វើពិធីជ្រមុជទឹក និង ទទួលអ្នកជឿថ្មីអោយចូលរួមក្នុងគ្រួសាររបស់ព្រះជាម្ចាស់ (កិច្ចការ ១០:៤៧-៤៨) :

☐ ភ្លាមៗ ។

☐ ក្រោយដែលបានបង្រៀនគោលជំនឿ និង ឃើញការជាក់ស្តែងអស់រយៈពេលយូរទៀត ។

៩- ពួកសាវ័កធ្វើពិធីជ្រមុជទឹកអោយអ្នកជឿថ្មីភ្លាមៗ មិនពន្យារពេលយូរទេ គឺថាចាប់ផ្តើមបង្រៀនពួកគេភ្លាមៗ អោយចេះប្រតិបត្តិតាមព្រះគ្រីស្ត ។ នៅក្នុងគម្ពីរ កិច្ចការ ២:៣៨-៤៧ យើងឃើញពីកិច្ចការដែលពួកសាវ័កធ្វើមុនគេចំពោះពួកអ្នកជឿថ្មី :

☐ ពួកសាវ័កគ្រាន់តែបង្រៀនអ្នកជឿថ្មី ពីគោលជំនឿប៉ុណ្ណោះ គឺមិនបង្រៀនបញ្ជាក់អំពីការប្រតិបត្តិតាមព្រះអម្ចាស់ទេ ។

(មានចំលើយមួយទៀត នៅទំព័រ ៤២)

«នៅថ្ងៃបន្ទាប់ អ្នកទាំងនោះធ្វើដំណើរទៅជិតដល់ក្រុងយ៉ុបប៉េ ។ ប្រមាណជាថ្ងៃត្រង់ លោកពេត្រុស/សិលាឡើងទៅអធិស្ឋាននៅលើដំបូលផ្ទះ ។ ពេលនោះ លោកឃ្លាន ចង់ពិសាបាយ ។ កាលគេកំពុងតែរៀបចំម្ហូបចំណីជូនលោកពិសា លោកបានលង់ស្មារតី និមិត្តឃើញផ្ទៃមេឃបើកចំហ ឃើញវត្ថុម៉្យាងដូចកំរាលតុមួយយ៉ាងធំ ដែលមានចងចុងជាយទាំងបួនជ្រុង ចុះពីលើមកដល់ដី ។ នៅលើកំរាលនោះ មានសត្វចតុប្បាទគ្រប់ប្រភេទ មានសត្វលូនវារ និង បក្សាបក្សី ។ មានព្រះសូរសៀងបញ្ជាមកគាត់ថា÷ "ពេត្រុស/សិលាអើយ ! ចូរសម្លាប់សត្វទាំងនេះបរិភោគទៅ !" ។

ប៉ុន្តែ លោកពេត្រុស/សិលាទូលទៅវិញថា÷ "ទេ ព្រះអម្ចាស់ទូលបង្គំ ពុំដែលទទួលទានអ្វីដែលវិន័យហាមឃាត់ ឬ មិនបរិសុទ្ធទាល់តែសោះ" ។ បន្ទាប់មក លោកពេត្រុស/សិលាបានឮព្រះសូរសៀងនោះ ជាលើកទីពីរថា÷ "អ្វីៗដែលព្រះជាម្ចាស់បានប្រោសឱ្យបរិសុទ្ធហើយ ចូរកុំចាត់ទុកថា វិន័យហាមឃាត់នោះឡើយ !" ។ ហេតុការណ៍នេះកើតមានដល់ទៅបីដង នៅទីបំផុត វត្ថុនោះក៏ឡើងទៅលើមេឃវិញភ្លាមបាត់ទៅ» ។

(កិច្ចការ ១០:៩-១៦)

៦- តើលោកពេត្រុសនិយាយពីអ្វី ដើម្បីពន្យល់ពីជំណឹងល្អប្រាប់លោកគ័រនេលាូស ព្រមទាំងសាច់ញាតិ និង មិត្តជិតជិតរបស់លោក ? (កិច្ចការ ១០:៣៤-៤៣)

- ☐ លោកពេត្រុសចាប់ផ្តើមបង្រៀនពីសៀវភៅយេរេមី ។
- ☐ លោកពេត្រុសនិយាយអំពីការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ និង ការលើកលែងទោសចំពោះអស់អ្នកដែលជឿលើព្រះអង្គ ។

៧- ក្រោយពីលោកពេត្រុសបានពន្យល់ពីសេចក្តីសំខាន់ទាំងអស់នោះអំពីព្រះយេស៊ូហើយ លោកពេត្រុស និង អ្នកជឿដែលទៅជាមួយលោកដឹងថា អាចទាក់ទងគេទៅទៀតជាមួយពួកអ្នកស្តាប់ទាំងនោះ ព្រោះពួកលោកពេត្រុសបានឃើញ និង ឮភស្តុតាងដែលបង្ហាញថា ពួកអ្នកទាំងនោះបានទទួលជឿហើយ គឺថាពួកលោក :

- ☐ បានឃើញពួកអ្នកស្តាប់នៅទីក្រុងសេសារេសរសើរតម្កើងព្រះជាម្ចាស់ ពោរពេញដោយព្រះវិញ្ញាណ ។
- ☐ រង់ចាំច្រើនខែទៀត ដើម្បីអាចដឹងច្បាស់ថា ពួកអ្នកជឿថ្មីព្យាយាមក្នុងជំនឿ ។

តើព្រះជាម្ចាស់ធ្វើអោយលោកពេត្រុសកែប្រែតំរិយាបទ ដែលគាត់មានចំពោះសាសន៍ដទៃ ដោយរបៀបណា ? ។

_____

_____

_____

_____

ព្រះជាម្ចាស់ជួយយើងឱ្យអាចឈ្នះលើចិត្តគំនិតប្រកាន់ពូជសាសន៍ ប្រពៃណី និង ទំនៀមទំលាប់ ដែលយើងមាន គឺចិត្តគំនិតប្រកាន់ដែលបណ្តាលអោយយើងមិនទាក់ទងរាប់អានមនុស្ស ដែលមានវប្បធម៌ផ្សេងពីយើង ។ មនុស្សដែលចង់ចំណាយលុយ និងថាមពលរបស់ខ្លួនទាំងប៉ុន្មាន ដើម្បីកសាងតែក្រុមជំនុំខ្លួនផ្ទាល់ប៉ុណ្ណោះ ច្រើនតែរអ៊ូតវ៉ា នៅពេលដែលយើងមានបំណងចង់បង្កើតក្រុមជំនុំសាខា ឬ ចាត់គ្រីស្តទូតឱ្យចេញទៅក្រៅប្រទេស ។ ហេតុនេះហើយ ទើបយើងចាំបាច់ត្រូវបង្រៀនក្រុមជំនុំរបស់យើងអំពី «ភារៈកិច្ចរបស់យើង ដែលត្រូវទៅផ្សាយដំណឹងល្អដល់មនុស្សដែលមិនទាន់បានឮពីដំណឹងល្អអំពីព្រះយេស៊ូនៅឡើយ» ។

៤- មុនពេលដែលលោកពេត្រុសធ្វើដំណើរចេញទៅ តើគាត់បានធ្វើអ្វី ដែលនាំអោយកិច្ចការបំរើរបស់គាត់នៅក្រុងសេសារេ មានជ័យជំនះរបស់ព្រះគ្រីស្ត ?

☐ គាត់បានអធិស្ឋាន ។

☐ គាត់បានទទួលប្រាក់កាសពីក្រុងយេរូសាឡឹម សំរាប់ការងាររបស់គាត់ ។

៥- អ្នកជឿដឹងថា លោកគ័រនេល្យូស និង គ្រួសាររបស់គាត់ចេះគោរពប្រណិប័តន៍ និង កោតខ្លាចព្រះជាម្ចាស់ ។ តើពួកអ្នកជឿទាំងនោះធ្វើដូចម្តេច ដើម្បីអោយមានទំនាក់ទំនងជាមួយមេគ្រួសារ ដែលកំពុងស្វែងរកព្រះជាម្ចាស់ ? (កិច្ចការ ១០:២៤)

☐ ពួកអ្នកជឿអញ្ជើញលោកគ័រនេល្យូស ទៅចូលរួមក្នុងកម្មវិធីធំ ដើម្បីផ្សាយដំណឹងល្អ ។

☐ ពួកគេទៅផ្ទះរបស់លោកគ័រនេល្យូសដែលបានអញ្ជើញពួកអ្នកដែលគាត់ស្គាល់ និង ទុកចិត្តអោយចូលរួម ។



តើអ្នកមានទំនាក់ទំនងនៅក្នុងតំបន់ ដែលមិនទាន់ទទួលដំណឹងល្អមួយណា ? ។

២- ក្រោយពីបានទទួលការនិមិត្តឃើញនេះហើយ តើលោកពេត្រុសបង្កើតក្រុមរបស់គាត់ ដោយរបៀបណា ? (កិច្ចការ ១០:២៣)

- ☐ គាត់ផ្ញើសំបុត្រពីក្រុងយ៉ុបប៉េ ទៅក្រុមជំនុំម្ដាយ នៅទីក្រុងយេរូសាឡឹម ។
- ☐ គាត់ចេញដំណើរ ដោយនាំអ្នកជឿថ្មីខ្លះពីក្រុងយ៉ុបប៉េទៅជាមួយ ។

៣- តើលោកពេត្រុស និង អ្នកជឿឯទៀតដែលមកពីក្រុងយ៉ុបប៉េធ្វើអ្វី ដើម្បីសម្របខ្លួនឱ្យត្រូវនឹងបណ្ដាជនមូលដ្ឋាននោះ ? (កិច្ចការ ១០:២៨-២៩)

- ☐ គេលែងមានគំនិតប្រកាន់ពូជសាសន៍ ។
- ☐ គេដាក់ច្បាប់ទម្លាប់សាសនាច្រើនលើអ្នកជឿថ្មី ដែលរស់នៅទីក្រុងសេសារេនោះ ។

រៀបចំក្រុមរបស់អ្នក ដោយអញ្ជើញសមាជិក របស់ក្រុមជំនុំអ្នកអោយជួយ

លោកពេត្រុសចេញទៅផ្សាយដំណឹងល្អ នៅទីក្រុងសេសារេ ជាមួយអ្នកជឿប្រាំមួយនាក់ (កិច្ចការ ១០:២៣, ១១:១២) ។

ទាំងព្រះយេស៊ូ ទាំងពួកសាវ័ករបស់ព្រះអង្គ មិនដែលចេញទៅផ្សាយដំណឹងល្អម្នាក់ឯងទេ ។ ត្រូវជ្រើសរើសមនុស្សម្នាក់អោយដឹកនាំក្រុម គឺជ្រើសយកអ្នកដែលស្រឡាញ់ប្រជាជននៅទីកន្លែងដែលក្រុមមានផែនការបង្កើតក្រុមជំនុំ ។ អ្នកនោះត្រូវទទួលខុសត្រូវលើការងាររបស់ក្រុម និង ត្រូវមានពេលសំរាប់បំពេញកិច្ចការបំរើនៅទីនោះផងដែរ ។

សម្របខ្លួនទៅតាមបណ្តាជនមូលដ្ឋាន នៅពេលដែលអ្នកទាក់ទងអោយស្គាល់ពួកគេ

សូមអាន កិច្ចការ ១០:១៧-២២ សាឡើងវិញ ។ តើអ្នកណាទៅជួបលោកពេត្រុសសិលា នៅពេលដែលគាត់កំពុងតែឆ្ងល់អំពីហេតុការណ៍ ដែលគាត់បាននិមិត្តឃើញនោះ ? ។

មូលហេតុមួយដែលនាំឱ្យចាត់តាំង និង រៀបចំពួកអ្នកដឹកនាំ គឺ :

☐ ដើម្បីបង្កើតច្បាប់ ។

☐ ដើម្បីការពារហ្វូងចៀមពីឆ្កែចចក ដែលប្រឆាំងនឹងក្រុមជំនុំ ។

សូមរកចំលើយនៅក្នុង កិច្ចការ ២០:២៨-៣១ ។

សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយសារក្រុមជំនុំរបស់អ្នកបង្កើតបានក្រុមជំនុំសាខាជាច្រើន !

របៀបបង្កើតក្រុមជំនុំមានពន្យល់ពិស្តារជាងនេះ នៅក្នុងកូនសៀវភៅ ទី ៣៧ « សៀវភៅណែនាំអំពីការបង្កើតក្រុមជំនុំ » ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើលោកពេត្រុសស្វែងរកការដឹកនាំរបស់ព្រះជាម្ចាស់ ដោយរបៀបណា ?

☐ ដោយការអធិស្ឋាន ។

☐ ដោយឈ្លោះប្រកែកជាមួយលោកយ៉ូហាន ។

«លោកពេត្រុស / សិលាអញ្ជើញអ្នកទាំងនោះចូលក្នុងផ្ទះ ឱ្យស្នាក់នៅជាមួយ ។ ព្រឹកឡើង លោកក៏ចេញដំណើរទៅជាមួយគេ»

(កិច្ចការ ១០:២៣)



លោកពេត្រុសស្តាប់តាមព្រះជាម្ចាស់ ហើយចេញទៅក្រុងសេសារេជាមួយអ្នកជឿមួយក្រុម ។ បើសិនជាព្រះជាម្ចាស់ត្រាស់ហៅអ្នកអោយទៅកន្លែងណាមួយផ្សេង តើអ្នកអាចលះបង់ទឹកចិត្តប្រកាន់ពូជសាសន៍របស់អ្នក ដើម្បីអាចប្រតិបត្តិតាមមហាបណ្តាំដែរឬទេ ?

☐ អាចលះបង់បាន ។

☐ មិនអាចលះបង់ទេ ។

៥:១៩, យ៉ាកុប ៥:១៤, ១ ពេត្រុស ៥:១-៤ ។ ដើម្បីបង្ហាត់បង្រៀននិស្សិតគ្រូគង្វាល សូមអញ្ជើញពួកគេឱ្យសិក្សាក្នុងកម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» នេះ ។

ពួកអ្នកដឹកនាំថែរក្សាហ្វូងចៀម ការពារកុំឱ្យឆ្កែចចកវាយប្រហារបាន (កិច្ចការ ២០:១៧, កិច្ចការ ជំពូក ២៨-៣១) ។ ឆ្កែចចកមុខជាវាយប្រហារក្រុមជំនុំថ្មី ដោយបំផ្លាស់បំប្រែសេចក្តីពិត ខិតខំលួចសមាជិករបស់ក្រុមជំនុំ និង បំបែកបំបាក់ការងារ ។



ហេតុអ្វី ? ។

ព្រះជាម្ចាស់បានរៀបចំលោកពេត្រុស ឱ្យអាចសម្របខ្លួនទៅតាមបណ្តាជនមកពីទីកន្លែងផ្សេង ដែលមានវប្បធម៌ផ្សេង ។ យើងក៏ត្រូវរៀបចំខ្លួនយើង ដើម្បីសម្របខ្លួនទៅតាមទំនៀមទំលាប់របស់ក្រុមវប្បធម៌ផ្សេង ឬ ក្រុមសង្គមផ្សេងដែរ ។ យើងធ្វើដូចនេះ ដើម្បីអាចមានទំនាក់ទំនងល្អជាមួយបណ្តាជន ដោយយល់ចិត្តគំនិតរបស់ពួកគេ និង ដើម្បីប្រុងប្រយ័ត្នមិនធ្វើអោយពួកគេអាក់អន់ចិត្ត ។

ស្វែងរកមេគ្រួសារដែលចាប់អារម្មណ៍អំពីដំណឹងល្អព្រះយេស៊ូ ដូចលោកគ័រនេលា្យសបានចាប់អារម្មណ៍ដែរ

នៅពេលដែលលោកពេត្រុសទៅដល់ក្រុងសេសារេ គាត់មិនបានស្វែងរកមនុស្សច្រើនដើម្បីអធិប្បាយ ឬក៏ប្រាប់គេឯងថា នឹងមានពិធីប្រកាសដំណឹងល្អនោះទេ ។ ផ្ទុយទៅវិញ សាវ័កពេត្រុសទៅស្វែងរកមេគ្រួសារ ដែលចាប់អារម្មណ៍អំពីដំណឹងល្អព្រះយេស៊ូ ។

តើពួកយូដាទិតៀនលោកពេត្រុស ដោយសារគាត់ធ្វើអ្វី ? ។

លោកពេត្រុសជំរាបរឿងហេតុគ្រប់យ៉ាងប្រាប់ពួកអ្នកជឿសាសន៍យូដានៅទីក្រុងយេរូសាឡឹម ដើម្បីធ្វើអោយពួកគេជឿជាក់ថាព្រះជាម្ចាស់ពិតជាបានធ្វើការអស្ចារ្យ នៅទីក្រុងសេសារេមែន ។

«ប្រសិនបើព្រះជាម្ចាស់ប្រទានព្រះអំណោយទានដល់គេ ដូចព្រះអង្គប្រទានមកយើង ដែលជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តដែរនោះ តើរូបខ្ញុំនេះ មានអំណាចអ្វីនឹងឃាត់ឃាំងព្រះជាម្ចាស់បាន ?កាលពួកអ្នកជឿបានឮសេចក្តីទាំងនោះ គេក៏ឈប់ចិត្ត ហើយនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ទាំងពោលថា៖ "សូម្បីតែសាសន៍ដទៃ ក៏ព្រះជាម្ចាស់ប្រោសប្រទានឱ្យកែប្រែចិត្តគំនិត ដើម្បីទទួលជីវិតដែរ !" » ។

(កិច្ចការ ១១:១៧-១៨)

ក្រុមជំនុំថ្មីត្រូវចាត់តាំង និង បង្ហាត់បង្រៀនអ្នកចាស់ទុំអោយក្លាយជាអ្នកដឹកនាំ ដើម្បីអោយពួកគេអាចចាត់ចែងកិច្ចការឃ្វាលក្នុងក្រុមជំនុំ ។ លោកប៉ូលបានធ្វើដូចនេះ ព្រមទាំងបង្គាប់អោយក្រុមជំនុំថ្មីទាំងអស់ធ្វើតាមនេះដែរ (កិច្ចការ ១៤:២៣, ទីតុស ១:៥) ។ សូមប្រៀបធៀបនឹង កិច្ចការ ១១:៣០, ១៥:២, ១ ធីម៉ូថេ

បង្ហាត់បង្រៀនអ្នកដឹកនាំ ដើម្បីឱ្យពួកគេការពាក្រុមជំនុំ ពីការបំផ្លាញរបស់មារសាតាំង

អារក្សតែងតែវាយប្រហារក្រុមជំនុំថ្មី ។ វាធ្វើអោយអ្នកជឿថ្មីធ្លាក់ទឹកចិត្តដោយសារការទិតៀន និង ការសង្ស័យ ។ លោកប៉ូលដាស់តឿនរំលឹកយើងថា៖ *«យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីអោយបានចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់»* ។

(កិច្ចការ ១៤:២២)



នៅក្នុងករណីរបស់ក្រុមជំនុំថ្មីនៅទីក្រុងសេសារេ ជនជាតិយូដាដែលគោរពតាមក្រិត្យវិន័យ ទិតៀនកិច្ចការដែលលោកពេត្រុសបានធ្វើ ។

«កាលលោកពេត្រុស / សិលាឡើងទៅដល់ក្រុងយេរូសាឡឹមវិញ អ្នកជឿដែលជាសាសន៍យូដានាំគ្នារិះគន់លោកថា៖ "លោកបានចូលក្នុងផ្ទះសាសន៍ដទៃ ហើយក៏បានបរិភោគជាមួយពួកគេថែមទៀតផង !"» ។ (កិច្ចការ ១១:២-៣)

«នៅថ្ងៃបន្ទាប់មកទៀត លោកបានទៅដល់ក្រុងសេសារេ ។ រីឯលោកគ័រនេលាូសវិញ គាត់បានអញ្ជើញញាតិសន្តាន និង មិត្តជិតជិត...» ។

(កិច្ចការ ១០:២៤)



តើលោកគ័រនេលាូសហៅអ្នកណាខ្លះ អោយមកជួបជុំគ្នា ? ។

លោកគ័រនេល្យូសហៅតែញាតិសន្តាន និង មិត្តជិតជិតអោយមកជួបជុំតែប៉ុណ្ណោះ ។ បើសិនជាមានមនុស្ស ដែលគ្រាន់តែចង់ចាំឈរមើល មកចូលរួមនោះ នឹងលែងមានបរិយាកាសនៃសេចក្តីស្រឡាញ់ និង ការទុកចិត្តគ្នាហើយ ។ បើផ្សាយដំណឹងល្អដល់មនុស្ស ដែលព្រះជាម្ចាស់រៀបចំចិត្តរួចហើយ នោះការងារនឹងទៅមុខលឿនណាស់ ! ។

ជំបួង យើងត្រូវផ្សាយដំណឹងល្អដល់អ្នក ដែលយើងស្គាល់សិន ។ ម៉្យាងទៀត យើងមិនត្រូវខិតខំដឹកនាំសមាជិករបស់ក្រុមជំនុំផ្សេងយកមកធ្វើជាសមាជិកយើងទេ ។ ព្រះជាម្ចាស់ហាមមិនឱ្យលួចកូនចៀមទេ (រ៉ូម ១៥:២០, ២ កូរិនថូស ១០:១៤-១៦) ។

បើសិនជាជំបួង យើងទៅទាក់ទងផ្សាយដំណឹងល្អដល់មេគ្រួសារសិន ហេតុការណ៍នៅទំព័របន្ទាប់នេះ មិនអាចកើតមានទេ :

ដើម្បីអោយសមាជិកទាំងអស់ ដែលមានអំណោយទានផ្សេងៗគ្នាអាចធ្វើការងាររួមជាមួយគ្នាបាន ពួកគេត្រូវមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ។ ព្រះយេស៊ូបង្គាប់យើងថា÷ «*ខ្ញុំអោយវិន័យថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រលាញ់គ្នាទៅវិញទៅមក អ្នករាល់គ្នាត្រូវស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ* » ។ (យ៉ូហាន ១៣:៣៤)

ដើម្បីអោយសមាជិកទាំងឡាយ ដែលមានអំណោយទានផ្សេងៗគ្នាអាចធ្វើការងាររួមជាមួយគ្នាបាន ពួកគេត្រូវមាន :

☐ អ្នកដឹកនាំដែលពូកែ និង ល្អ ។

☐ សេចក្តីស្រឡាញ់ ។

សេចក្តីស្រឡាញ់កសាងក្រុមជំនុំ ។ មនុស្សដែលធ្វើការងាររួមជាមួយគ្នា ចាំបាច់ត្រូវចេះអត់ធ្មត់ អត់ទោស និង ចេះបន្ទាបខ្លួន ។ ការទិតៀន ការច្រណែនឈ្នានីស និង អំនួត នឹងបំផ្លាញឯកភាពរបស់ក្រុមជំនុំ ។

ដោយសារយើងមានសេចក្តីស្រឡាញ់ យើងជួយសមាជិកទាំងអស់អោយចូលរួមធ្វើកិច្ចការខ្ពះរបស់ព្រះអម្ចាស់ ជាពិសេស ការផ្សាយដំណឹងល្អដល់ក្រុមគ្រួសាររបស់ពួកគេផ្ទាល់ ។

ដូចគ្នានេះដែរ ក្រុមជំនុំជារូបកាយរបស់ព្រះគ្រីស្ត ។ ហើយព្រះ-ជាម្ចាស់បានប្រទានអោយសមាជិកម្នាក់ៗមានមុខងារបំរើផ្សេងៗគ្នា ដើម្បីអោយពួកគេអាចប្រើអំណោយទានទាំងនោះ សំរាប់បំពេញកិច្ចការនោះ (អេភេសូ ៤:១១-១៦) ។ ដើម្បីអោយក្រុមជំនុំអាចមានការស្រុះស្រួលគ្នា និង សេចក្តីស្រឡាញ់ដូចនេះ ក្រុមជំនុំត្រូវមាន «ការរៀបចំល្អ» ។

នៅក្នុងក្រុមជំនុំ ដែលមានការរៀបចំល្អ តើសមាជិកធ្វើការរបៀបណា ?

- ☐ សមាជិកទាំងអស់បំពេញមុខងារបំរើតែមួយដូចគ្នា ។
- ☐ សមាជិកម្នាក់ៗបំពេញមុខងារបំរើតាមអំណោយទាន ដែលព្រះជាម្ចាស់ប្រទានអោយ ដោយធ្វើការបំរើរួមជាមួយគ្នា ជារូបកាយតែមួយ ។
- ☐ មានតែសមាជិកពីរ ឬ បីនាក់ធ្វើកិច្ចការបំរើនេះ ។



© Project WorldReach © SEAN

នៅកន្លែងថ្មី យើងចាប់ផ្តើមធ្វើការផ្សាយដំណឹងល្អ ក្នុងចំណោមបុរស និង ក្រុមគ្រួសាររបស់គេ ។



រៀបចំក្រុមជំនុំថ្មីអោយអាចធ្វើការងារ (ផ្សាយដំណឹងល្អ និង ធ្វើកិច្ចការបំរើ)រួមជាមួយគ្នា ដោយក្តីស្រលាញ់ ។

គោលដៅរបស់ជំហាននេះ គឺណែនាំប្រមូលពួកអ្នកជឿថ្មីនៃក្រុមជំនុំថ្មីអោយបំពេញកិច្ចការនៅក្នុងក្រុមជំនុំ និង ផ្សព្វផ្សាយដំណឹងល្អដល់សាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ ។

ការសំខាន់ គឺត្រូវបង្រៀន និង ណែនាំប្រមូលសមាជិកក្រុមជំនុំថ្មីអោយផ្សាយដំណឹងល្អ ដើម្បីឱ្យការផ្សាយដំណឹងល្អនោះ ក្លាយជាបំណង និង សកម្មភាពរបស់ក្រុមជំនុំ តាំងពីពេលចាប់ផ្តើមរហូតទៅ ។

ម៉្យាងទៀត ក្រុមបង្កើតក្រុមជំនុំត្រូវណែនាំប្រមូលសមាជិកក្រុមជំនុំថ្មីអោយចេះជួយធ្វើកិច្ចការបំរើរបស់ក្រុមជំនុំ ។ ១ កូរិនថូស ជំពូក ១២ ប្រៀបធៀបក្រុមជំនុំជាមួយរូបកាយរបស់មនុស្ស ។ រូបកាយមនុស្សមានច្រើនផ្នែក ហើយផ្នែកទាំងនោះធ្វើការរួមគ្នាដើម្បីប្រយោជន៍រួម ។ ផ្នែកទាំងនោះផ្សេងគ្នាទាំងអស់ តែផ្នែកនិមួយៗ មានមុខនាទីសំខាន់មួយសំរាប់ធ្វើឱ្យរូបកាយដំណើរការ ។ ភ្នែក ត្រចៀក ជើង បេះដូង និង ផ្នែកផ្សេងៗទៀតរបស់រូបកាយទាំងមូល ធ្វើការងាររួមគ្នា ដើម្បីគោលបំណងតែមួយ ។

តើអ្នកនឹងបង្រៀនអ្នកជឿថ្មី ឱ្យចេះប្រតិបត្តិតាមព្រះអម្ចាស់ដូចនេះ តាំងពីដំបូងដែរឬទេ ? (កិច្ចការ ២:៣៧-៤៧) ។

ចាប់ផ្តើមធ្វើសកម្មភាព និង ការប្រជុំថ្វាយបង្គំ ដែលពួកអ្នកជឹកនាំថ្មីរបស់ក្រុមជំនុំអាចនឹងធ្វើបាន ។

នៅក្នុងទីកន្លែង ដែលទើបនឹងទទួលដំណឹងល្អ ការប្រជុំដំបូងៗ ត្រូវមានភាពសាមញ្ញ ដើម្បីអោយសមាជិកមូលដ្ឋាន ឆាប់អាចជឹកនាំការប្រជុំបាន ព្រោះថានៅកន្លែង ដែលទើបនឹងមានការផ្សាយដំណឹងល្អ នៅមិនទាន់មានគ្រូគង្វាល ដែលមានបទ-ពិសោធន៍នៅឡើយទេ ។

ការធ្វើពិធីកាច់នំប៉័ងជួយក្រុមជំនុំថ្មីអោយយកចិត្តទុកដាក់ចំពោះការថ្វាយបង្គំ និង ផ្តល់អោយក្រុមជំនុំថ្មីបានទទួលផលប្រយោជន៍ពីពិធីកាច់នំប៉័ងនេះ ។

តើក្រុមជំនុំរបស់ពួកសាវ័កដំបូង ឧស្សាហ៍ធ្វើពិធីកាច់នំប៉័ងដែរឬទេ ? (សូមអាន កិច្ចការ ២:៤១-៤២, ២០:៧) ។ _____

ពន្យល់ដំណឹងល្អអោយច្បាស់លាស់

យើងនិយាយអំពីដំណឹងល្អសុទ្ធសាធ គឺអំពីចរិតលក្ខណៈរបស់ព្រះគ្រីស្ត មូលហេតុដែលព្រះអង្គសុគត និង មានព្រះជន្មរស់ឡើងវិញដើម្បីយើង អំពីការលើកលែងទោសអំពើបាប និង អំពីព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ (លូកា ២៤:៤៥-៤៨, កិច្ចការ ២:៣៨, ១ កូរិនថូស ១៥:១-៥) ។

ពេលអធិប្បាយ លោកពេត្រុសមិនធ្វើអោយគេចាប់អារម្មណ៍លើខ្លួនគាត់ទេ តែគាត់នាំគេអោយថ្វាយសិរីរុងរឿងទៅព្រះគ្រីស្តវិញ ។

«ពេលលោកពេត្រុស/ សិលាមកដល់ លោកគ័រនេលាូសចេញទៅទទួលក្រាបចុះទៀបជើងលោក ។ ប៉ុន្តែ លោកពេត្រុស /សិលាចាប់គាត់អោយក្រោកឡើង ទាំងពោលថា÷ "អញ្ជើញក្រោកឡើង ខ្ញុំក៏ជាមនុស្សដែរទេតើ !" » ។

(កិច្ចការ ១០:២៥-២៦)

សូមអាន កិច្ចការ ១០:៣៤-៤៣ ។ តើសាវ័កពេត្រុសធ្វើទីបន្ទាល់នៅផ្ទះលោកគ័រនេល្យូសអំពីអ្វី ?

☐ អំពីការកែប្រែខ្លាំង ក្នុងជីវិតរបស់លោកពេត្រុសផ្ទាល់ ។

☐ អំពីអ្វីៗដែលព្រះគ្រីស្តបានធ្វើសំរាប់មនុស្សយើង ។

នៅពេលផ្សាយដំណឹងល្អ ពួកសាវ័កតែងតែប្រកាសពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ត និង ការដែលព្រះអង្គលើកលែងទោសអោយរួចពីអំពើបាប ។



បើតាមសេចក្តីដែលសាវ័កពេត្រុសប្រកាសប្រាប់ពួកគេ តើព្រះ-យេស៊ូជាអ្នកណា ? (ខ ៣៦) ។ _____

នៅពេលដែលអ្នកជឿថ្មីកែប្រែចិត្តគំនិត យើងគួរធ្វើពិធីជ្រមុជទឹកអោយអ្នកទាំងនោះ ។ នេះជារបៀបដែលយើងបញ្ជាក់អោយអ្នកជឿដឹងជាក់ថា ព្រះជាម្ចាស់លើកលែងទោសអោយគេ និង ទទួលពួកគេជាសមាជិកនៃព្រះសហគមន៍របស់ព្រះជាម្ចាស់ផងដែរ ។ (ត្រូវធ្វើតាមគោលលទ្ធិ និង របៀបរបបអំពីពិធីជ្រមុជទឹករបស់ក្រុមជំនុំរបស់អ្នក) ។ ពិធីជ្រមុជទឹកជាជំហានទីមួយរបស់អ្នកជឿថ្មី ដើម្បីបញ្ជាក់ពីជំនឿ និង ការបែរចេញពីអំពើបាបរបស់គាត់ (កិច្ចការ ២:៣៨, ៨:៣៦-៣៨, ២២:១៦) ។

កែប្រែចិត្តគំនិត មិនមែនគ្រាន់តែឈប់ប្រព្រឹត្តអំពើបាបជាក់ស្តែងជាងគេប៉ុណ្ណោះទេ ។ ការកែប្រែចិត្តគំនិតដោយស្មោះ គឺជាការកែប្រែចិត្តគំនិតពីអំពើបាបជាប់រហូត ដែលបង្ហាញចេញជាការប្រតិ-បត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ។ យើងបង្រៀនយ៉ាងឆាប់រហ័ស អោយពួកអ្នកជឿថ្មីដែលបានកែប្រែចិត្តគំនិត និង ទទួលពិធីជ្រមុជទឹក ចេះចូលរួមក្នុងពិធីកាច់នំប៉័ង អធិស្ឋាន សិក្សាព្រះបន្ទូល ដាក់ដង្វាយ ផ្សាយដំណឹងល្អ និង ជាពិសេសមានសេចក្តីស្រឡាញ់ ។

ពួកសាវ័កបាននៅជាមួយពួកអ្នកជឿថ្មីមួយរយៈ ដើម្បីលើកទឹកចិត្ត និង ណែនាំពួកគេ ។ មិនត្រូវបោះបង់ចោលទារក ដែលទើបនឹងកើតទេ ។

ក្រោយពីមនុស្សមានបំណងចង់ទទួលព្រះគ្រីស្តជាព្រះអម្ចាស់ និង ជាព្រះសង្គ្រោះហើយ ពួកសាវ័កសុំឱ្យពួកអ្នកទាំងនោះធ្វើកិច្ចការ បីយ៉ាង :

១- កែប្រែចិត្តគំនិតពីអំពើបាប (កិច្ចការ ២:៣៨) ។

២- ប្រកាសពីជំនឿរបស់ពួកគេលើព្រះយេស៊ូ (រ៉ូម ១០:៩) ។

៣- បញ្ជាក់ពីជំនឿ និង ការកែប្រែចិត្តគំនិតរបស់ពួកគេ ដោយទទួលពិធីជ្រមុជទឹក (កិច្ចការ ២:៤១) ។

ពួកសាវ័កបញ្ជាក់ថា អ្នកថ្វាយខ្លួនបានសង្គ្រោះហើយ ដោយ :

☐ ចេញសញ្ញាប័ត្រអោយពួកគេ ។

☐ ធ្វើពិធីជ្រមុជទឹកអោយពួកគេ ។

តើព្រះយេស៊ូបានធ្វើកិច្ចការពីរយ៉ាងអ្វីខ្លះ ដោយសារឫទ្ធានុភាព របស់ព្រះជាម្ចាស់ ? (ខ ៣៧-៣៨) ។

_____ និង _____

តើមនុស្សធ្វើដូចម្តេចចំពោះព្រះអង្គ ? (ខ ៣៩) ។

_____

តើព្រះជាម្ចាស់ធ្វើដូចម្តេចចំពោះព្រះយេស៊ូ ? (ខ ៤០) ។

_____

តើអ្នកជឿលើព្រះអង្គបានទទួលអ្វីខ្លះ ? (ខ ៤៣) ។ _____

_____

យើងត្រូវផ្សាយដំណឹងល្អដូចសាវ័កពេត្រុស គឺថាប្រកាសពីកិច្ចការ បីយ៉ាង ដែលព្រះអម្ចាស់បានពន្យល់នៅក្នុងលូកា ២៤:៤៧-៤៨ :

- ព្រះយេស៊ូជាអ្នកណា ។
- ការសុគតលើឈើឆ្កាង និង ការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូ ដើម្បីលោះបាបយើង ។
- ការលើកលែងទោសអំពើបាប ។

នៅពេលផ្សាយដំណឹងល្អ ពួកសាវ័កតែងតែបង្រៀនអំពីកិច្ចការទាំងបីយ៉ាងនៃការសង្គ្រោះ ។ នៅក្នុងសៀវភៅកិច្ចការរបស់ពួកសាវ័ក ពេលដែលពួកសាវ័កប្រកាសដំណឹងល្អ ពួកគេតែងតែនិយាយអំពី :

- ☐ បុគ្គលិកលក្ខណៈរបស់ព្រះគ្រីស្ត ។
- ☐ ការសុគតលើឈើឆ្កាង និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។
- ☐ ការលើកលែងទោសអំពើបាប ។
- ☐ កិច្ចការទាំងបីនេះ ។

ឧទាហរណ៍ខាងក្រោមនេះ បង្ហាញថា ពួកសាវ័កតែងតែចែកចាយប្រាប់ពីកិច្ចការទាំងបីរបស់ដំណឹងល្អនេះរហូត គឺ :

- លោកពេត្រុស និង មនុស្សបីពាន់នាក់នៅថ្ងៃបុណ្យ ថ្ងៃ ទីហាសិប (កិច្ចការ ២:១៤-៣៩) ។
- លោកពេត្រុសនៅថែវសាឡូម៉ូន (កិច្ចការ ៣:១១-២៦) ។

ពួកគេបានទទួលសញ្ញាដៅសំគាល់ពីព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលដែលពួកគេទទួលជឿ (សូមមើល អេភេសូ ១:១៣, កិច្ចការ ២:៣៨, កូឡូស ២:១១-១២, រ៉ូម ៨:១១) ។

ពួកសាវ័កក៏មិនពន្យារពេលធ្វើពិធីជ្រមុជទឹកដែរ : *«ពេលនោះ លោកពេត្រុស /សិលាមានប្រសាសន៍ថា៖ "គ្មាននរណាអាចឃាត់យើងមិនអោយធ្វើពិធីជ្រមុជទឹកជូនអស់អ្នក ដែលបានទទួលព្រះ-វិញ្ញាណដ៏វិសុទ្ធ ដូចជាយើងបានទទួលដែរនោះទេ !" »* ។

(កិច្ចការ ១០:៤៧)



«លោកក៏បញ្ជាអោយគេធ្វើពិធីជ្រមុជទឹក ជូនអ្នកទាំងនោះក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ។ បន្ទាប់មក ពួកគេសុំអោយលោកស្នាក់នៅជាមួយគេបានយូរថ្ងៃបន្តិចទៀត » (កិច្ចការ ១០:៤៨) ។

ព្រះបន្ទូល ។ ពួកអ្នកជឿជាសាសន៍យូដា ដែលមកជាមួយលោកពេត្រុស / សិលាងឿងឆ្ងល់ណាស់ ដោយព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធប្រទានអោយសាសន៍ដទៃដែរ ។ ព្រោះគេបានឮសាសន៍ដទៃទាំងនោះ និយាយភាសាចំឡែកអស្ចារ្យ ព្រមទាំងលើកតម្កើងព្រះជាម្ចាស់ផង » ។

(កិច្ចការ ១០:៤៤-៤៦)



តើក្រុមគ្រួសាររបស់លោកគ័រនេល្យូស ទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលណា ?

☐ នៅពេលដែលពួកគេទទួលជឿដំណឹងល្អភ្លាម ។

☐ ក្រោយពីបានរៀនច្រើនខែមក ។

- លោកពេត្រុស និង លោកយ៉ូហានៅមុខក្រុមប្រឹក្សាជាន់ខ្ពស់សាសន៍យូដា (កិច្ចការ ៤:៨-១២) ។
- លោកស្តេផានអធិប្បាយមិនបានចប់ គេក៏សម្លាប់គាត់មុន (កិច្ចការ ជំពូក ៧) ។
- លោកពេត្រុសនៅផ្ទះរបស់លោកគ័រនេល្យូស (កិច្ចការ ១០:៣៤-៤៣) ។
- លោកប៉ូលនៅក្រុងអង់ទីយ៉ូកក្នុងស្រុកពីស៊ីឌី (កិច្ចការ ១៣:១៦-៤១) ។
- លោកប៉ូលនៅទីក្រុងអាថែន លោកប៉ូលនិយាយមិនបានចប់ទេ ដោយសារគេនិយាយចំអកពាក្យសំដីគាត់ (កិច្ចការ ១៧:១៦-៣៤) ។
- លោកប៉ូលនៅមុខសាសន៍យូដា លោកប៉ូលនិយាយមិនបានចប់ទេ ព្រោះពួកយូដាបានស្រែកអោយគាត់ (កិច្ចការ ២២:១-២១) ។
- លោកប៉ូលនៅមុខព្រះរាជាអគ្រីប៉ា (កិច្ចការ ២៦:១-២៩) ។

© Project WorldReach © SEAN

ពួកសាវ័កតែងតែនិយាយអំពីកិច្ចការបីយ៉ាង ដែលសំខាន់បំផុតនេះ នៅពេលផ្សាយដំណឹងល្អ ។ តើកិច្ចការទាំងបីនោះ គឺអ្វីខ្លះ ?

១- ព្រះយេស៊ូជា_____។

២- ការសុគត និង ការមាន_____របស់ព្រះយេស៊ូ ។

៣- ការលើក_____ ។

ក្រុមជំនុំនិមួយៗ ត្រូវប្រកាសពីសេចក្តីពិតទាំងនេះ ជារៀងរាល់ថ្ងៃ ។

ការផ្សាយដំណឹងល្អ មិនមែនជាកម្មវិធី «ពិសេស» ដែលត្រូវប្រារព្ធធ្វើជាសកម្មភាពធំៗនោះទេ ។ យើងគួរតែបង្រៀនពួកអ្នកជឿថ្មីរបស់ក្រុមជំនុំសាខា ឱ្យចេះផ្សាយដំណឹងល្អប្រាប់សាច់ញាតិ និង មិត្តភក្តិរបស់ពួកគេ តាមរបៀបរបស់ពួកសាវ័កដែរ ។

«បងប្អូនអើយ រីឯខ្ញុំវិញ កាលខ្ញុំមកជូនដំណឹងអំពីគំរោងការដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់ដល់បងប្អូន ខ្ញុំមិនបានប្រើសំនួនវោហារ ឬ ប្រាជ្ញាខ្ពស់ៗទេ ។ ពេលខ្ញុំនៅជាមួយបងប្អូន ខ្ញុំយល់ឃើញថា មិនគួរគប្បីអោយខ្ញុំដឹងអ្វី ក្រៅពីព្រះយេស៊ូគ្រីស្តនោះឡើយ ជាពិសេសអំពីព្រះយេស៊ូគ្រីស្ត ដែលបានសោយទីវង្គតនៅលើឈើឆ្កាង» ។ (១ កូរិនថូស ២:១-២)

បញ្ជាក់ពីការថ្វាយខ្លួនរបស់ពួកអ្នក ដែលទទួលដំណឹងល្អ



អស់អ្នកដែលបានទៅជួបជុំនៅផ្ទះរបស់លោកគ័រនេលាូស បានថ្វាយខ្លួនទាំងអស់គ្នា :

«លោកពេត្រុស / សិលាកំពុងមានប្រសាសន៍នៅឡើយ ស្រាប់តែព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមកសណ្ឋិតលើអស់អ្នក ដែលស្តាប់

© Project WorldReach © SEAN